Click here for English version




# ផ្តល់ជូនកូនរបស់អ្នកនូវការចាប់ផ្តើមដ៏ល្អបំផុតក្នុងជីវិត

## ការណែនាំសម្រាប់ការជ្រើសរើសសាលារៀន

# ការជ្រើសរើសសាលាដ៏ស័ក្តិសម

មាតាបិតាគ្រប់រូបតែងតែចង់បានអ្វីដែលល្អបំផុតសម្រាប់កូនរបស់ពួកគេ ហើយការសម្រេចចិត្តដ៏ធំមួយដែលអ្នកត្រូវធ្វើក្នុងនាមអ្នកជាមាតាបិតានោះគឺជ្រើសរើសសាលាដែលស័ក្តិសមសម្រាប់កូនៗរបស់អ្នក។

ការសម្រេចចិត្តដ៏ធំបំផុតមួយដែលអ្នកត្រូវធ្វើក្នុងនាមជាមាតាបិតាគឺការជ្រើសរើសសាលារៀនដែលស័ក្តិសមសម្រាប់កូនអ្នក។ វាជាការសម្រេចចិត្តដ៏ធំមួយ ដែលមានឥទ្ធិពលយ៉ាងធំធេងដល់ជីវិតរបស់ពួកគេទាំងស្រុង ដូច្នេះទើបវាជារឿងសំខាន់ដែលត្រូវគិតឲ្យបានដិតដល់លើជម្រើសរបស់អ្នកជាមុន!





# ការចាប់ផ្តើម

អ្នកគួរស្វែងរកសាលាដែលស័ក្តិសមភ្លាមបន្ទាប់ពីកូនតូចរបស់អ្នកបានចាប់កំណើត។ សាលារៀនជាច្រើនផ្តល់ជូននូវកម្មវិធីអប់រំទាំងស្រុងចាប់ពីថ្នាក់មត្តេយ្យរហូតដល់បញ្ចប់ថ្នាក់អនុវិទ្យាល័យ។ ដូច្នេះអ្នកប្រហែលជាកំពុងស្វែងរកសាលាមត្តេយ្យដំបូងសម្រាប់កូនៗអ្នក នៅពេលពួកគេមានអាយុ 6 ខែ ព្រោះពួកគេអាចនឹងចាប់ផ្តើមការសិក្សាតាំងពីអាយុមួយឆ្នាំ។

## គន្លឹះសំខាន់ៗ


**ចាប់ផ្តើមស្វែងរកសាលាឲ្យបានលឿន**
ចាប់ផ្តើមស្វែងរកជម្រើសសាលាឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ វាមិនលឿនពេកនោះទេក្នុងការចាប់ផ្តើមស្វែងរកសាលាសម្រាប់កូនអ្នក។

**ទុកពេលសម្រាប់ការស្វែងរក**
ចំណាយពេលតាមដែលអ្នកត្រូវការដើម្បីស្វែងរកជម្រើសទាំងអស់។ វាជាការសម្រេចចិត្តដ៏សំខាន់មួយ។

**ធ្វើការសាកសួរ**
ទទួលយកមតិកាន់តែច្រើនពីសាលានីមួយៗតាមដែលអាចធ្វើបាន។ វានឹងជួយអ្នកក្នុងការសម្រេចចិត្តយកជម្រើសដ៏ល្អបំផុត។

**លោកអ្នកត្រូវការជំនួយមែនទេ?**

លោកអ្នកអាចចូលក្នុងក្រុម **Cambodia Parent Network** នៅលើហ្វេសបុក ដើម្បីទទួលបានចំណេះដឹងបន្ថែមពីមាតាបិតាដែលបានបញ្ជូនកូនរបស់ពួកគេទៅសាលាដែលអ្នកកំពុងពិចារណាចង់បញ្ជូនកូនអ្នកទៅ។



# ពិចារណាពីទីតាំង

ការពិចារណាដ៏សំខាន់បំផុតមួយក្នុងការជ្រើសរើសសាលារៀនគឺការជ្រើសរើសទីតាំង។ ខណៈពេលដែលការជ្រើសរើសសាលារៀនដោយផ្អែកលើតែកេរ្តិ៍ឈ្មោះ និងសម្ភារៈបរិក្ខារជារឿងល្អ អ្នកក៏ត្រូវគិតថាអ្នកនឹងត្រូវជូនកូនអ្នកទៅសាលា រួចទៅយកពួកគេមកវិញជារៀងរាល់ថ្ងៃ។ អ្នកគួរគិតអំពីកត្តាមួយចំនួនដូចជាភាពងាយស្រួលក្នុងការធ្វើដំណើរ នៅពេលអ្នកជ្រើសរើសសាលារៀនរបស់កូនអ្នក។ នេះគឺជាផ្នែកសំខាន់មួយនៃជីវិតប្រចាំថ្ងៃរបស់មាតាបិតាជាច្រើននៅទូទាំងពិភពលោកដែលពួកគេទិញផ្ទះនៅក្នុងទីតាំងដែលនៅជិតសាលារៀនល្អៗដើម្បីងាយស្រួលសម្រាប់ពួកគេក្នុងការធ្វើដំណើរទៅវិញទៅមកជារៀងរាល់ថ្ងៃ។

## គន្លឹះសំខាន់ៗ

**សាកធ្វើដំណើរតាមផ្លូវនោះ**

អ្នកគួរសាកល្បងធ្វើដំណើរពីផ្ទះរបស់អ្នកទៅសាលារៀននីមួយៗក្នុងបញ្ជីរបស់អ្នក។ តើវាងាយស្រួលក្នុងការធ្វើដំណើរទៅផ្លូវនោះជារៀងរាល់ថ្ងៃដែរឬទេ?

**ធ្វើការសាកសួរ**

អ្នកគួរទៅកាន់សាលាអំឡុងពេលសិស្សចេញពីសាលា ហើយអ្នកនឹងអាចសាកសួរសំនួរជាច្រើនទៅកាន់មាតាបិតាសិស្ស។

**ទៅកាន់សាលានីមួយៗ**

អ្នកគួរធ្វើការណាត់ជួបដើម្បីទៅមើលសាលារៀននីមួយៗជាលក្ខណៈផ្លូវការ ព្រមទាំងសាកសួរសំណួរជាច្រើនតាមដែលអាចធ្វើបាន។



**លោកអ្នកត្រូវការជំនួយមែនទេ?**

លោកអ្នកអាចចូលក្នុងក្រុម **Cambodia Parent Network** នៅលើហ្វេសបុក ដើម្បីជួបជាមួយមាតាបិតាដែលបានបញ្ជូនកូនរបស់ពួកគេទៅសាលាដែលអ្នកកំពុងពិចារណាចង់បញ្ជូនកូនអ្នកទៅ រួចសួរពួកគេពីអ្វីដែលពួកគេចូលចិត្ត និងមិនចូលចិត្តអំពីសាលានោះ។

# សាលារៀនរដ្ឋ ឬសាលារៀនឯកជន?

អ្នកទទួលបានទៅតាមអ្វីដែលអ្នកចំណាយ ដូចជារឿងជាច្រើនផ្សេងទៀតក្នុងជីវិតដែរ។ ខណៈពេលដែលសាលារៀនរដ្ឋនៅប្រទេសកម្ពុជាកំពុងមានការរីកចម្រើនយ៉ាងឆាប់រហ័ស និងទទួលបានការកោតសរសើរអំពីភាពងាយស្រួលក្នុងការចុះឈ្មោះចូលរៀន និងមានការតាំងចិត្តខ្ពស់ ចំណែកឯសាលាឯកជន និងសាលាលំដាប់អន្តរជាតិជាច្រើនក៏មានជាសម្ភារៈបរិក្ខារ និងជំនាញច្បាស់លាស់ក្នុងការផ្តល់នូវបទពិសោធន៍នៃការអប់រំផ្ទាល់ខ្លួនបន្ថែមទៀតផងដែរ។

ខណៈពេលដែលការអប់រំល្អមានតម្លៃថ្លៃ ប៉ុន្តែតម្លៃនៃការអប់រំគឺមិនអាចកាត់ថ្លៃបានទេ។ ដូច្នេះវាជារឿងសំខាន់ក្នុងការស្រាវជ្រាវអំពីសាលានៅក្នុងតំបន់របស់អ្នកដោយមានការយកចិត្តទុកដាក់។

---

## នេះជាកត្តាមួយចំនួនដែលត្រូវពិចារណា៖

**ចូលអ្នកមើលឲ្យជិតដល់លើប្រវត្តិ និងកំណត់ត្រារបស់ពួកគេ។**
តើវាជាសាលារៀនថ្មីមែនទេ? តើពួកគេមានកេរ្តិ៍ឈ្មោះល្អទេ?
តើគ្រូបង្រៀនរបស់ពួកគេមានលក្ខណៈសម្បត្តិល្អដែរឬទេ?



**អ្នកគួរព្យាយាមនិយាយជាមួយមាតាបិតាដែលកូនរបស់ពួកគេទៅសិក្សានៅសាលានេះក្នុងពេលបច្ចុប្បន្ន។**
តើពួកគេគិតយ៉ាងណាដែរ? តើពួកគេសប្បាយចិត្តទេ?
តើកូនរបស់ពួកគេរីករាយជាមួយសាលានេះទេ?



**អ្នកគួរទៅមើលទីលានលេងកីឡារបស់សាលា។**
តើពួកគេលើកទឹកចិត្តកុមារឲ្យចូលរួមក្នុងសកម្មភាពកីឡាដែរឬទេ?

**ចុះតន្ត្រី និងសិល្បៈវិញ?**
តើកុមារត្រូវបានលើកទឹកចិត្តឲ្យមានភាពច្នៃប្រឌិតដែរឬទេ?
កត្តាទាំងនេះអាចធ្វើឲ្យមានភាពខុសគ្នាយ៉ាងខ្លាំងចំពោះការអប់រំទាំងស្រុងរបស់ពួកគេ។



**អ្នកគួរមើលលើទំហំរបស់ថ្នាក់រៀនថា** តើក្នុងថ្នាក់នីមួយៗមានកុមារប៉ុន្មាននាក់?
តើគ្រូបង្រៀនត្រូវបានគាំទ្រយ៉ាងត្រឹមត្រូវក្នុងថ្នាក់ដែរឬទេ?

**អ្នកគួរពិចារណាមិនត្រឹមតែលើថ្លៃសិក្សារបស់សាលាប៉ុណ្ណោះទេ** ប៉ុន្តែអ្នកគួរគិតបញ្ចូលទាំងថ្លៃចុះឈ្មោះ អាហារថ្ងៃត្រង់របស់សាលា ថ្លៃឯកសណ្ឋាន និងថ្លៃសកម្មភាពនានា។
តើការបង់ថ្លៃសាលាសរុបស័ក្តិសមនឹងថវិការបស់អ្នកទេ?



# របៀបស្វែងរកសាលារៀនដ៏ល្អបំផុតដែលនៅជិតលោកអ្នកបំផុត

អ្នកអាចស្វែងរកព័ត៌មានដែលមានសារៈសំខាន់ជាច្រើនអំពីសាលារៀនដែលជិតអ្នកបំផុតតាមរយៈការស្វែងរកលើប្រព័ន្ធអ៊ីនធើណិត។

អ្នកគួរកត់ចំណាំអំពីសាលាណាដែលជិតអ្នកបំផុត បន្ទាប់មកធ្វើការផ្ទៀងផ្ទាត់ជាមួយគេហទំព័រដូចជា **International Schools Database**។ វាជាប្រភពដែលមានអត្ថប្រយោជន៍ និងព័ត៌មានល្អៗជាច្រើនអំពីសាលាអន្តរជាតិក្នុងរាជធានីភ្នំពេញ។

អ្នកនឹងរកឃើញនូវព័ត៌មាន និងតំណភ្ជាប់ (links) ល្អៗជាច្រើននៅ**ទីនេះ** ហើយអ្នកត្រូវចាំជានិច្ចថាត្រូវពិនិត្យមើលឲ្យជិតដល់នៅលើគេហទំព័ររបស់សាលានីមួយៗ នៅពេលអ្នកធ្វើការសម្រិតសម្រាំងដើម្បីបញ្ចូលសាលាទៅក្នុងបញ្ជីរបស់អ្នក។

---

## គន្លឹះសំខាន់ៗ

**កត់ត្រាលើបញ្ជីដែលអ្នកចង់បាន**
តើលក្ខណៈពិសេស និងអត្ថប្រយោជន៍អ្វីខ្លះដែលសំខាន់សម្រាប់អ្នក? ប្រៀបធៀបសាលានីមួយៗទៅនឹងបញ្ជីដែលអ្នកចង់បាន។

**បង្កើតបញ្ជីខ្លី**
អ្នកអាចធ្វើការស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធើណិតដើម្បីបង្កើតបញ្ជីខ្លីមួយ បន្ទាប់មកធ្វើការណាត់ជួបដើម្បីទៅមើលសាលាដែលមានក្នុងបញ្ជីរបស់អ្នក។

**សូមចូលមើលការវាយតម្លៃ**
សូមពិនិត្យមើលថាតើមានការវាយតម្លៃផ្ទាល់ខ្លួនណាមួយអំពីសាលារៀនដែលអ្នកកំពុងពិចារណា។



# សូមទៅកាន់សាលារៀនដោយផ្ទាល់

មុនពេលអ្នកចុះឈ្មោះកូនៗរបស់អ្នក សូមប្រាកដថាអ្នកបានទៅសាលារៀនដែលមាននៅក្នុងបញ្ជី
របស់អ្នក។ នេះនឹងបង្ហាញថាសាលានោះមានរូបរាងដូចម្តេច។

ជារឿយៗសាលានឹងរៀបចំកម្មវិធីបើកបង្ហាញដែលអញ្ជើញសិស្សានុសិស្ស និងក្រុមគ្រួសាររបស់ពួកគេ
ទៅទស្សនាសាលា។ សូមកុំភ្លេចពិនិត្យឲ្យដិតដល់នូវអ្វីដែលត្រូវបានផ្តល់ជូន។ តើវាត្រូវនឹងអ្វីដែលបាន
ពណ៌នានៅលើគេហទំព័ររបស់ពួកគេដែរឬទេ? តើក្មេងៗមើលទៅមានភាពសប្បាយរីករាយដែរឬទេ?
តើគ្រូបង្រៀនមានភាពរួសរាយរាក់ទាក់ដែរឬទេ?

**ធ្វើការសាកសួរ** អ្នកត្រូវប្រាកដថាអ្នកមានព័ត៌មានទាំងអស់ដែលអ្នកត្រូវការដើម្បីធ្វើការជ្រើសរើស
សាលាដែលស័ក្តិសមសម្រាប់កូនរបស់អ្នក!

# តើមានវិធីអ្វីខ្លះដើម្បីបង់ថ្លៃសាលារៀនជាមុន?

ចំពោះគ្រួសារភាគច្រើន ថ្លៃសាលាគឺមានសារៈសំខាន់ (តែងតែមានតម្លៃថ្លៃ) សម្រាប់ថវិកាប្រចាំឆ្នាំរបស់ពួកគេ។ មាតាបិតានៅទូទាំងប្រទេសកម្ពុជាតែងតែពិបាកក្នុងស្វែងរកប្រាក់ដើម្បីបង់ថ្លៃសាលាប្រចាំឆ្នាំ ដូច្នេះវាពិតជាមានសារៈសំខាន់ណាស់ក្នុងការស្វែងយល់អំពីរបៀបដែលអ្នកនឹងត្រូវបង់ថ្លៃសាលាមុនពេលអ្នកចុះឈ្មោះកូនរបស់អ្នក។ នេះជារបៀបរៀបចំថវិកាសម្រាប់ថ្លៃសាលា៖

- គណនាថ្លៃសាលាទាំងអស់ រួមទាំងថ្លៃចុះឈ្មោះ ថ្លៃសិក្សា អាហារថ្ងៃត្រង់ ឯកសណ្ឋាន ថ្លៃសកម្មភាពសាលា និងការចំណាយផ្សេងៗទៀត។
- អ្នកគួរធ្វើការសាកសួរអំពីការបញ្ចុះតម្លៃ។ តើសាលារបស់អ្នកផ្តល់ការបញ្ចុះតម្លៃសម្រាប់ការបង់ថ្លៃសាលាសរុបជាមុនទេ? តើមានការបញ្ចុះតម្លៃសម្រាប់ការបង់លឿន '**early bird**' ទេ? តើពួកគេផ្តល់ការបញ្ចុះតម្លៃសម្រាប់កូនដែលចូលរៀនបន្ទាប់ទេ?
- តើសាលារបស់អ្នកផ្តល់ផែនការក្នុងការបង់ប្រាក់ ឬមានសហការជាមួយធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុដែលផ្តល់ប្រាក់កម្ចីទេ? ដូចនេះអ្នកអាចទាញយកអត្ថប្រយោជន៍ពីការបញ្ចុះតម្លៃលើការបង់ថ្លៃសាលាពេញមួយឆ្នាំ ខណៈពេលដែលអ្នកអាចទូទាត់ប្រចាំខែជាមួយធនាគារក្នុងតម្លៃសមរម្យ។
- សូមពិនិត្យមើលថវិកាគ្រួសារដែលនៅសល់របស់អ្នក។ តើអ្នកអាចមានលទ្ធភាពបង់ថ្លៃសាលាដែរឬទេ?



BRED BANK CAMBODIA | ADVANCE



# ស្វែងយល់បន្ថែមអំពីកម្ចីបង់រំលស់ថ្លៃសាលា ADVANCE ពីធនាគារ ប្រេដ ខេមបូឌា

កម្ចីបង់រំលស់ថ្លៃសាលា ADVANCE របស់យើងខ្ញុំបានសហការជាមួយគ្រឹះស្ថានអប់រំឈានមុខគេរបស់ប្រទេសកម្ពុជា និងជួយមាតាបិតានៅទូទាំងប្រទេសដោយផ្តល់ថវិការលើការអប់រំដ៏ល្អបំផុតសម្រាប់កូនៗរបស់ពួកគេ។

ចាប់ពីថ្នាក់មត្តេយ្យរហូតដល់សាកលវិទ្យាល័យ យើងខ្ញុំអាចផ្តល់កម្ចីដែលពួកគេត្រូវការក្នុងការបង់ថ្លៃសាលាជាមុន ខណៈពេលដែលពួកគេអាចទូទាត់សងវិញជាមួយថវិកាប្រចាំខែរបស់គ្រួសារពួកគេ។

ក្រុមការងាររបស់យើងខ្ញុំនៅទីនេះដើម្បីជួយលោកអ្នក។ មិនថាសាលារៀនណាក៏ដោយដែលអ្នកជ្រើសរើសសម្រាប់កូនរបស់អ្នក មិនថាជាសាលាដៃគូសហការរបស់យើងខ្ញុំ ឬជាជម្រើសផ្សេងទៀតណាមួយរបស់អ្នកទេ អ្នកអាចស្នើសុំប្រាក់កម្ចីបង់រំលស់ថ្លៃសាលា ADVANCE ដែលមានតម្លៃល្អបំផុត និងទូទាត់សងវិញជាប្រចាំខែក្នុងតម្លៃសមរម្យ។

ស្វែងយល់បន្ថែមនៅថ្ងៃនេះ ដោយទូរសព្ទទៅកាន់លេខ **1800 20 1234** ដោយឥតគិតថ្លៃ ឬអ៊ីមែល **advance@bredcambodia.com.kh**

BRED BANK CAMBODIA | ADVANCE

# គ្រឹះស្ថានអប់រំជាដៃគូរបស់យើងខ្ញុំ

### វិទ្យាស្ថាន ខេមអេដ
វិទ្យាស្ថានផ្តល់ការអប់រំកម្រិតឧត្តមសិក្សាផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ ដែលមានការទទួលស្គាល់ និងមានអាសយដ្ឋាននៅរាជធានីភ្នំពេញ។

### សាលា ហ្វីតព្រីនអន្តរជាតិ
សាលាអន្តរជាតិផ្តល់ការអប់រំគុណភាពខ្ពស់ចាប់ពីថ្នាក់មត្តេយ្យដល់ថ្នាក់ទី 12 ដែលមានអាសយដ្ឋាននៅសាខាទួលទំពូង និងទួលគោក រាជធានីភ្នំពេញ។

### សាលាអន្តរជាតិ ម៉ាកសឹន
គ្រឹះស្ថានសិក្សាដែលផ្តល់ការអប់រំលំដាប់ពិភពលោកសម្រាប់កុមារអាយុចាប់ពី 1 ឆ្នាំ ដល់ 12 ឆ្នាំ ជាមួយនឹងបរិក្ខារដ៏ល្អឥតខ្ចោះ ដែលមានអាសយដ្ឋាននៅផ្ទះលេខ 561 ផ្លូវ 1980 រាជធានីភ្នំពេញ។

### សាលាអន្តរជាតិ ដឹហ្គីវីងទ្រី
សាលាអន្តរជាតិដ៏ល្អឯកផ្តល់ជូននូវកម្មវិធីសិក្សាដ៏ពេញលេញចាប់ពីថ្នាក់មតេយ្យរហូតដល់បឋមសិក្សា ដែលមានអាសយដ្ឋាននៅផ្ទះលេខ 17 ផ្លូវ 71 បឹងកេងកង រាជធានីភ្នំពេញ។

### សាលាវេស្ទើនអន្តរជាតិ
សាលារៀនបង្កើតឡើងក្នុងឆ្នាំ 2003 ដែលជាសាលាដ៏ពេញនិយមក្នុងការផ្តល់ការអប់រំចាប់ពីថ្នាក់មត្តេយ្យដល់ថ្នាក់ទី 12 ព្រមទាំងមាន 16 សាខានៅជុំវិញរាជធានីភ្នំពេញ ក្រុងតាខ្មៅ និងខេត្តព្រះសីហនុ។

### សាលា Authentic Advance Academy
ថ្នាក់រៀនដែលមានកម្មវិធីសិក្សាជាច្រើនមុខរួមមានតែក្វាន់ដូ ការរាំបាឡេ ការរាំចង្វាក់ហ្សូមបា មនុស្សយន្ត និងកម្មវិធីជាច្រើនផ្សេងទៀត ដែលមានអាសយដ្ឋានស្ថិតនៅផ្សារទំនើប Fun Mall ជាន់ទី 3 ផ្លូវលេខ 315 រាជធានីភ្នំពេញ។



សូមពិនិត្យមើលការផ្តល់ជូនរបស់កម្ចីបង់រំលស់ **ADVANCE** យើងខ្ញុំ នៅលើ **គេហទំព័រធនាគារ ប្រេដ** ។


BRED
BANK
CAMBODIA
ADVANCE